00940470

E284/4/7

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ជ/អ.ជ.ត.ក(២៨)
Case File/Dossier N°. 002/19-09-2007-ECCC-TC/SC(28)

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 23-Jul-2013, 16:00
CMS/CFO: Sann Rada

**នៅចំពោះមុខ៖**

ចៅក្រម គង់ ស្រ៊ឹម ប្រធាន
ចៅក្រម Chandra Nihal JAYASINGHE
ចៅក្រម Agniezska KLONOWIECKAMILART
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Judge Florence Ndepele Mwachande MUMBA
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម យ៉ា ណារិន

| | |
|---|---|
| **កាលបរិច្ឆេទឯកសារ៖** | ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ |
| **ភាសាដើម៖** | ខ្មែរ/អង់គ្លេស |
| **ចំណាត់ថ្នាក់ឯកសារ៖** | សាធារណៈ |

---

# សេចក្តីសម្រេចលើបណ្តឹងសាទុក្ខផ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២

## <u>សេចក្តីសង្ខេបនៃសំអាងហេតុ</u>

---

**<u>សហព្រះរាជអាជ្ញា</u>**

ជា លាង
Andrew CAYLEY

**<u>សហមេធាវីជនជាប់ចោទ នួន ជា</u>**

សុន អរុណ
Victor KOPPE

**<u>ជនជាប់ចោទ</u>**

ខៀវ សំផន

នួន ជា

**<u>សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ

Elisabeth SIMONNEAU FORT

**<u>សហមេធាវីជនជាប់ចោទ ខៀវ សំផន</u>**

គង់ សំអុន

Anta GUISSÉ
Arthur VERCKEN
Jacques VERGÈS

1. **អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក”) ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យក្នុងអំឡុងថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ (“អង្គជំនុំជម្រះតុលាការកំពូល” និង “អ.វ.ត.ក”) បានទទួល“បណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីរនៃសំណុំរឿង ០០២” ដែលបានដាក់នៅថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៣ (“បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា”)[1] និង“បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង និងសារណាតបទៅនឹងបណ្តឹងសាទុក្ខបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីររបស់សហប្រះរាជអាជ្ញា” ដែលដាក់នៅថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ (“បណ្តឹងសាទុក្ខរបស់ នួន ជា” និង“សារណាតបរបស់ នួន ជា”)[2]។

2. បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា និងបណ្តឹងសាទុក្ខរបស់ នួន ជា (ជាមួយគ្នា “បណ្តឹងសាទុក្ខ”) ជាប់ពាក់ព័ន្ធទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការ បំបែក កិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿងបច្ចុប្បន្ន(“សំណុំរឿង ០០២”) និងកម្រិតវិសាលភាពនៃការជំនុំជម្រះលើកទីមួយ (“សំណុំរឿង ០០២/០១-II”) ត្រឹមបទចោទ ដែលជាប់ពាក់ព័ន្ធទៅនឹងការជម្លាសដោយបង្ខំក្នុងដំណាក់កាលទីមួយ និងពីរ[3] និងការសម្លាប់នៅទួលពោធិ៍ជ្រៃ។ សេចក្តីសម្រេចដែលរងការជំទាស់នេះ ចេញបន្ទាប់ពីអង្គជំនុំជម្រះតុលាការកំពូលបានចេញសេចក្តីសម្រេច ដោយប្រកាសមោឃភាពលើដីកាបំបែកប្រហាក់ប្រហែលគ្នាកាលពីលើកដំបូងរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២ (“ដីកាបំបែកលើកទីមួយនៃសំណុំរឿង ០០២” និង “សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល”)[4]។

---

[1] E284/2/1។

[2] E284/4/1។

[3] ប្រតិចារិក ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ ឯកសារលេខ E1/176.1, ទំព័រ ១ ដល់ ៤។ សេចក្តីសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលចេញថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣, ឯកសារលេខ E284 ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ (“សេចក្តីសម្រេចដែលរងការជំទាស់”)។

[4] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ពន្ធ័នឹងវិសាលភាពនៃសំណុំរឿង ០០២/០១ ឯកសារលេខ E163/5/1/13, ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣។

## ភាពអាចទទួលយកបាន

3. អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា បណ្តឹងសាទុក្ខនេះបានដាក់ទាន់ពេល តាមវិធាន ៣៩(៣) នៃវិធានផ្ទៃក្នុង និង វិធាន ១០៧(១) នៃវិធានផ្ទៃក្នុង ហើយអាចទទួលយកបាន តាមវិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុង។

## អង្គសេចក្តី

4. សហព្រះរាជអាជ្ញាលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយមិនបានអនុវត្តតាមបទដ្ឋានផ្នែកច្បាប់ ក្នុងការបំបែកកិច្ចដំណើរការនីតិវិធី ដែលបានកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល[5]។ សហព្រះរាជអាជ្ញាបានជំទាស់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស ក្នុងការសន្និដ្ឋានថា វិសាលភាពដែលមានស្រាប់នៃសំណុំរឿង ០០២/០១-II មានលក្ខណៈជាតំណាងគ្រប់គ្រាន់នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយពុំបានបន្ថែមទីតាំង ស-២១[6], និងមានកំហុសក្នុងការសន្និដ្ឋានថា ការបន្ថែម ស-២១ នឹងធ្វើឱ្យពន្យារពេលដល់ការជំនុំជម្រះដោយឥតហេតុផល[7]។ ព្រះរាជអាជ្ញាបន្ថែមទៀតថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសក្នុងការលើកឡើងពីការបន្តគ្នាជាហូរហែនៃការជំនុំជម្រះនាពេលអនាគត ទោះបីជាដឹងអំពីអាយុ និងសុខភាពរបស់ជនជាប់ចោទទាំងពីរក៏ដោយ[8]។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាស្នើសុំអង្គជំនុំជម្រះតុលាការកំពូល កែប្រែសេចក្តីសម្រេចដែលរងការជំទាស់ ត្រង់ចំណុចដាក់បញ្ចូល ស-២១ ទៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១-II[9]។

5. នួន ជា លើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស ក្នុងការសម្រេចបំបែកសំណុំរឿង ០០២ ជាថ្មីម្តងទៀត[10] និងពុំបានបញ្ចូលបទចោទដែលទាក់ទងទៅនឹងបទចោទប្រល័យពូជសាសន៍ និងសហករណ៍ និងការដ្ឋានធ្វើការ ក្នុងសំណុំរឿង ០០២/០១-II[11]។ ដូច្នេះ នួន ជា ស្នើសុំអង្គជំនុំជម្រះតុលាការកំពូល ទុកជាមោឃៈនូវសេចក្តីសម្រេចដែលរងការជំទាស់នេះ ដែលមានការប៉ះពាល់ដល់ដីកាបំបែក

---

[5] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២០ ដល់ ២៧។

[6] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៨ ដល់ ៥០។.

[7] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៥១ ដល់ ៧៥។

[8] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៧៦ ដល់ ៧៩។

[9] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៨៥។

[10] បណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៩ ដល់ ២៧។

[11] បណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ២៨ ដល់ ៥៥។

នាពេលអនាគត ឬ ជាជម្រើសម្យ៉ាងទៀត ពង្រីកវិសាលភាពនៃសំណុំរឿង ០០២/០១-II ដោយរួមបញ្ចូលបទចោទប្រល័យពូជសាសន៍ និងបទចោទទាក់ទងនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងសហករណ៍ និងការដ្ឋានធ្វើការ[12]។

## ក. ភាពមិនសមស្របដែលរងការចោទប្រកាន់ នៃការបង្គាប់បំបែកដីកាក្នុងសំណុំរឿង ០០២

6. អង្គជំនុំជម្រះតុលាការកំពូលរំលឹកថា ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងតាមវិធាន ៨៩ *ស្ទួនពីរ* នៃវិធានផ្ទៃក្នុង ក្នុងការបំបែកសំណុំរឿងមួយទៅជាការជំនុំជម្រះដាច់ដោយឡែកពីគ្នា មានលក្ខណៈទូលំទូលាយ។ ក្នុងការបង្ហាញពីការរំលោភបំពាននៅក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិ ដែលបណ្តាលឱ្យមានការប៉ះពាល់ដល់សិទ្ធិរបស់ខ្លួន គឺជាបន្ទុករបស់ម្ចាស់បណ្តឹងសាទុក្ខ ដែលបន្ទុកនេះមានលក្ខណៈធ្ងន់ធ្ងរ។ សម្រាប់សំអាងហេតុដែលនឹងត្រូវចេញយ៉ាងពេញលេញ នៅក្នុងសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរក្នុងពេលឆាប់ៗខាងមុខនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលការបំបែកកិច្ចដំណើរការនីតិវិធីជាថ្មីនៃសំណុំរឿង ០០២ គឺតម្រូវដោយផលប្រយោជន៍យុត្តិធម៌នោះ មានភាពសមហេតុផល ក្នុងការធានាឱ្យមានអន្តរាគមន៍លើបណ្តឹងសាទុក្ខ។

7. ហេតុដូចនេះ បដិសេធលើសំណើរបស់ នួន ជា ដែលស្នើសុំឱ្យមោឃភាពលើដីកាបំបែកលើកទីពីរនៃសំណុំរឿង ០០២។

## ខ. កំហុសដែលត្រូវបានចោទប្រកាន់ នៅក្នុងទម្រង់នៃដីកាបំបែកលើកទីពីរនៃសំណុំរឿង ០០២

8. អង្គជំនុំជម្រះតុលាការកំពូលរំលឹកថា ក្នុងការប្រកាសពីភាពគ្មានសុពលភាពនៃដីកាបំបែកលើកទីមួយនៃសំណុំរឿង ០០២ បញ្ជាក់ឱ្យឃើញថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ពុំបានប៉ះពាល់ដល់ការវាយតម្លៃឡើងវិញរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការបំបែកកិច្ចដំណើរការនៃសំណុំរឿង ០០២ ប៉ុន្តែ ការបំបែកកិច្ចដំណើរការនីតិវិធីជាថ្មី តម្រូវឱ្យមានផែនការច្បាស់លាស់សម្រាប់ការជំនុំជម្រះលើរឿងក្តីទាំងមូលទៅលើបទចោទដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងការពិចារណាយ៉ាងត្រឹមត្រូវទៅលើភាពជាតំណាង ដែលសមហេតុផល នៅក្នុងការជំនុំជម្រះដាច់ដោយឡែកពីគ្នា[13]។

---

[12] បណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៨៤។

[13] សេចក្តីសម្រេចរបស់ អង្គជំនុំជម្រះតុលាការកំពូល កថាខណ្ឌ ៥០។

9. អង្គជំនុំជម្រះសាលាដំបូងបានចាត់ទុក "សញ្ញាណនៃភាពជាតំណាង នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ថាគ្មានន័យ"[14] ហើយបានបន្តកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០១ ចាប់ពីចំណុច ដែលខ្លួនបានធ្វើ នៅពេលដែលអង្គជំនុំជម្រះតុលាការកំពូលបានចេញសេចក្តីសម្រេចរបស់ខ្លួន។ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសថា ខ្លួន"មានភាពមន្ទិលសង្ស័យចំពោះការកំណត់ពីគម្រោងសម្រាប់ការជំនុំជម្រះនាពេលអនាគតថា នឹងអាចក្លាយជាផែនការមួយដ៏មានអត្ថន័យ"[15] ហើយ បានសម្រេចមិនដោះស្រាយលើបញ្ហាត្រង់ចំណុច ថាតើ ការជំនុំជម្រះបន្តបន្ទាប់នេះអាចនឹងត្រូវធ្វើឡើងតាមរបៀបណានោះទេ ហើយជាពិសេស ថាតើ ការជំនុំជម្រះលើកទីពីរក្នុងសំណុំរឿង ០០២ ("សំណុំរឿង ០០២/០២") នឹងអាចចាប់ផ្តើមនៅពេលណាឡើយ[16]។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងបានស្នើសុំឱ្យមាន"កិច្ចប្រជុំរៀបចំសវនាការនៅចុងឆ្នាំ ដែលបញ្ហានេះអាចនឹងត្រូវឱ្យមានការពិនិត្យជាថ្មីឡើងវិញ បន្ទាប់ពីមានការប្រែប្រួលនៃស្ថានភាពនានាដែលអាចកើតមាន"[17]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការខកខានរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការមិនអនុវត្តតាមសេចក្តីបង្គាប់ គឺជាកំហុសអង្គច្បាប់ និងកំហុសក្នុងការអនុវត្តឆន្ទានុសិទ្ធិ។

10. សម្រាប់សំអាងហេតុដែលនឹងត្រូវបង្ហាញយ៉ាងពេញលេញជាលាយលក្ខណ៍អក្សរក្នុងពេលឆាប់ៗខាងមុខនេះ អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា ដោយពិចារណាទៅលើភាពវ័យចំណាស់ និងសុខភាពដែលកាន់តែចុះខ្សោយរបស់ជនជាប់ សញ្ញាណនៃភាពជាតំណាងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ មានសុពលភាពសម្រាប់បញ្ហានៃការបំបែកកិច្ចដំណើរការនីតិវិធី ក្នុងសំណុំរឿង ០០២ ដើម្បីអាចអង្គជំនុំជម្រះសម្រេចពីភាពជាចម្បង ក្នុងការដោះស្រាយលើបទចោទដែលត្រូវបានបំបែក។ បន្ថែមលើនេះទៀត អង្គជំនុំជម្រះយល់ឃើញថា សំណុំរឿង ០០២/០១ អាចនឹងមានភាពជាតំណាងសមហេតុផលនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយមិនត្រឹមតែពង្រីកវិសាលភាពដើម្បីបញ្ចូលមន្ទីរ ស-២១ ដែលជាសំណើរបស់សហព្រះរាជអាជ្ញាប៉ុណ្ណោះទេ ថែមទាំងគប្បីបញ្ចូលបទចោទប្រល័យពូជសាសន៍ សហករណ៍ និងការដ្ឋានធ្វើការដែលជាសំណើរបស់ នួន ជា។ ទោះជាយ៉ាងណាក្តី ការពិតដែលថា ទោះបីជាបានចំណាយអស់រយៈពេល

---

[14] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៩៩ (សេចក្តីបញ្ជាក់បន្ថែម)។

[15] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១៥៣។

[16] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១៥៤ ដល់ ១៥៥។

[17] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១៥៥។

១៤ ខែ លើការរៀបចំសវនាការក្នុងសំណុំរឿង ០០២[18] និងបានទុកចំហាចោលនូវវិសាលភាពនៃសំណុំរឿង ០០២/០១ អស់រយៈពេលមួយឆ្នាំ[19]សម្រាប់ការប្រែប្រួលក៏ដោយ អង្គជំនុំជម្រះសាលាដំបូងនៅតែពុំមានការកែប្រែគោលជំហរពីដំបូងរបស់ខ្លួនលើការបំបែកកិច្ចដំណើរការនីតិវិធី ដើម្បីធ្វើការសម្របសម្រួលទៅតាមសំណើរបស់ភាគី និងដោះស្រាយការបារម្ភណាមួយរបស់ភាគីទាក់ទងនឹងបច្ច័យនៃការបំបែកិច្ចដំណើរនីតិវិធីសាជាថ្មី សម្រាប់ការជំនុំជម្រះណាមួយនាពេលអនាគតនោះ បានបង្ហាញឱ្យឃើញថា អង្គជំនុំជម្រះសាលាដំបូង ប្រហែលជាពុំបានរៀបចំធ្វើការជំនុំជម្រះលើបទចោទដែលនៅសេសសល់នៅក្នុងដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០២/០១។

11. ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា នៅក្នុងកាលៈទេសៈបច្ចុប្បន្ននេះ ក្នុងការបង្គាប់ពង្រីកវិសាលភាពសំណុំរឿង ០០២/០១ និងក្នុងការតម្រូវឱ្យអង្គជំនុំជម្រះសាលាដំបូងកែសម្រួលផែនការរបស់ខ្លួននោះ នឹងអាចបណ្តាលឱ្យមានការពន្យារពេលដែលឥតចាំបាច់។ ក្នុងកាលៈទេសៈបច្ចុប្បន្ន ក្តីបារម្ភចំពោះការរៀបចំសវនាការឱ្យមានប្រសិទ្ធភាពនៃបទចោទទាំងអស់ ដែលនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ចាំបាច់ជាងការលើកឡើងដែលថា សំណុំរឿង ០០២/០១ គឺមានភាពជាតំណាងសមស្របនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ចំណាត់ការដែលសមស្របនៅក្នុងដំណាក់កាលនេះ គឺត្រូវបង្គាប់ថា បទចោទដែលពុំបានបញ្ចូលក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ នឹងក្លាយជាវិសាលភាពនៃសំណុំរឿង ០០២/០២ ដើម្បីឱ្យការបូកបញ្ចូលគ្នារវាងវិសាលភាពនៃសំណុំរឿង ០០២/០១ និង០០២/០២ ក្លាយជាតំណាងសមស្របនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ អាស្រ័យហេតុនេះ សំណុំរឿង ០០២/០២ ត្រូវចាប់ផ្តើមឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទីពីរ ដើម្បីឱ្យសម្រេចបាននូវបញ្ហានេះ នាពេលបច្ចុប្បន្ននេះ បានក្លាយជាបញ្ហាសំខាន់។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលបង្គាប់ការិយាល័យរដ្ឋបាលនៃ អ.វ.ត.ក ស្វែងរកភ្លាមៗនូវលទ្ធភាពនៃការបង្កើតនៅក្នុងអង្គជំនុំជម្រះសាលាដំបូង នូវក្រុមប្រឹក្សាជំនុំជម្រះទីពីរនៃចៅក្រមជាតិ និងចៅក្រមអន្តរជាតិ ដើម្បីស្តាប់ និងជំនុំជម្រះសំណុំរឿង ០០២/០២។

[18] ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ ត្រូវបានចេញនៅថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១០ ដែលជាកាលបរិច្ឆេទមួយដដែលអង្គជំនុំជម្រះសាលាដំបូងទទួលបានសំណុំរឿង ០០២ ដោយអនុលោមតាមវិធាន ៦៩(៣) នៃវិធានផ្ទៃក្នុង។ ការជំនុំជម្រះក្នុងសំណុំរឿង ០០២ បានចាប់ផ្តើមនៅថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១។ សូមមើលប្រតិចារិក ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារលេខ E1/13.1។

[19] សូមមើលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល កថាខណ្ឌ ១៧, ៣៧ និង ៤៦។

12. អាស្រ័យហេតុនេះ សំណើរបស់សហព្រះរាជអាជ្ញាសុំបន្ថែម ស-២១ និងសំណើរបស់ នួន ជា សុំបន្ថែមបទចោទប្រល័យពូជសាសន៍ ព្រមទាំងសហករណ៍ និងការដ្ឋានធ្វើការទៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ ត្រូវបានបដិសេធចោល។

## ផ្នែកសម្រេចសេចក្តី

13. យោងតាមសំអាងហេតុខាងលើ **អង្គជំនុំជម្រះតុលាការកំពូលសម្រេច:**

**ទទួលយក**បណ្តឹងសាទុក្ខ តាមវិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុង;

**បដិសេធ**បណ្តឹងសាទុក្ខលើអង្គសេចក្តី;

**បង្គាប់**ថា សវនាការភស្តុតាងក្នុងសំណុំរឿង ០០២/០២ នឹងត្រូវចាប់ផ្តើមឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន បន្ទាប់ពីកិច្ចបិទការពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០១, និងថា សំណុំរឿង ០០២/០២ នឹងត្រូវរួមបញ្ចូលជាអប្បបរមានូវបទចោទទាក់ទងនឹង ស-២១, ការដ្ឋានធ្វើការ, សហករណ៍ និងបទចោទប្រល័យពូជសាសន៍។

សេចក្តីសម្រេចបច្ចុប្បន្ន បានចេញទៅតាមពេលកំណត់ដែលមានចែងក្នុង វិធាន ១០៨(៤)(*ស្ទួន*)(ខ) នៃវិធានផ្ទៃក្នុង ហើយចេញតែសេចក្តីសង្ខេបនៃសំអាងហេតុ។ ចំពោះសំអាងហេតុពេញលេញនឹងចេញក្នុងពេលឆាប់ៗខាងមុខ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រីម**